# សេចក្ដីថ្លែងការណ៍ស្ដីពី

# ការរកឃើញបឋមការប៉ាន់ប្រមាណរហ័សលើផលប៉ះពាល់នៃសារធាតុពុល

# នៅក្នុងជម្លោះព្រំដែនកម្ពុជា-ថៃ (កក្កដា-កញ្ញា ២០២៥)

ការប៉ាន់ប្រមាណរហ័សរយៈពេលបួនថ្ងៃ ដែលធ្វើឡើងរួមគ្នាដោយអង្គចម្រុះ/អង្គការសង្គមស៊ីវិលចំនួន ៨ ជាមួយដៃគូក្នុងខេត្ត និងភាគីពាក់ព័ន្ធ បានទទួលព័ត៌មានស៊ីគ្នាទាក់ទងនឹងការចោទប្រកាន់អំពីផ្សែងពុល/សារធាតុគីមី និងរោគសញ្ញាពាក់ព័ន្ធក្នុងអំឡុងពេលប៉ះទង្គិចគ្នានៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃនាពេលថ្មីៗនេះ ដែលវាបានបង្កើនការព្រួយបារម្ភយ៉ាងខ្លាំងអំពីផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងចំពោះសហគមន៍មូលដ្ឋាន និងបរិស្ថាន ត្រូវឲ្យមានការឆ្លើយតបភ្លាមៗ និងប្រកបដោយនិរន្តរភាព។ អង្គការទាំងនោះបានប៉ាន់ប្រមាណរួមគ្នាបានរកឃើញស្ថានភាពបឋមសំខាន់ៗ ដូចខាងក្រោម៖

1. មានការផ្ដល់សញ្ញាយ៉ាងខ្លាំងអំពីវត្តមានសារជាតុគីមីពុលដែលប្រើក្នុងអំឡុងពេលជម្លោះ ដែលបង្កហានិភ័យជាបន្តបន្ទាប់ដល់សហគមន៍នៅតាមតំបន់ព្រំដែន។

2. បទសម្ភាសន៍ជាមួយទាហានកម្ពុជា និងអ្នកភូមិជួរមុខបានឃើញថាផ្សែងពុលដែលបង្កគ្រោះថ្នាក់ត្រូវបានបាញ់ដោយទាហានថៃតាមរយៈយន្តហោះ និងយន្តហោះគ្មានមនុស្សបើក (ដ្រូន) ក្នុងអំឡុងពេលប៉ះទង្គិចគ្នា និងសូម្បីតែក្រោយកិច្ចព្រមព្រៀងឈប់បាញ់។ ពួកគេបានបង្ហាញរោគសញ្ញារួមមាន៖ ការពិបាកដកដង្ហើម បំពង់កស្ងួត ខ្សោយកម្លាំង ឈឺក្បាល និងសញ្ញាអាចឲ្យខូចខាតសួត។ កំណត់ត្រា វេជ្ជសាស្ត្រដែលទទួលបានដោយក្រុមវាយតម្លៃបានបញ្ជាក់ថា រោគសញ្ញាមួយចំនួននេះមាននៅក្នុងអ្នកជំងឺដែលជាទាហាន និងអ្នកភូមិ។

3. អ្នកភូមិដែលរស់នៅក្បែរសមរភូមិតាមបណ្ដោយជួរភ្នំដងរែកក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ រួមទាំង ភូមិឈើទាលគង ក្បែរប្រាសាទព្រះវិហារ និងភូមិថ្មដូន, ភូមិហនុមាន និងភូមិតាមន្ត (តាមាន់) ក្បែរប្រាសាទតាមន្ត បានរាយការណ៍ពីការស្លាប់រង្គាលនៃសត្វចិញ្ចឹម និងសត្វបក្សីរបស់អ្នកភូមិ ក៏ដូចជាជ្រូក ហើយជ្រូកដែលនៅរស់ទទួលរងជម្ងឺស្បែកធ្ងន់ធ្ងរ។ កសិករក្នុងស្រុកក៏

សង្កេតឃើញថាដើមដំណាំ និងឈើហូបផ្លែខ្លះប្រែទៅជាពណ៌ប្រផេះ និងខ្លះទៀតមានពណ៌ក្រហម និងមិនមានសុខភាពល្អ។

4. សហគមន៍ផ្លាស់ទីលំនៅពីភូមិជួរមុខដូចជាប្រាសាទតាក្របី, ប្រាសាទតាមាន់ និងតំបន់ប្រាសាទព្រះវិហារ បានសម្តែងការភ័យខ្លាចយ៉ាងខ្លាំងក្នុងការវិលត្រឡប់ទៅផ្ទះវិញ ដោយសារតែវត្តមានគ្រាប់មិនទាន់ផ្ទុះ និងផ្សែងពុល។ អ្នកភូមិជាច្រើនបានរាយការណ៍ថា ការប្រើប្រាស់ទឹកភ្លៀងដែលរក្សាទុកក្នុងពាងបណ្តាលឱ្យមានអាការៈក្អួត រលាកស្បែក និងរាគ។ ករណីទាំងនេះបង្កើនការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរអំពីការបំពុលដែលអាចកើតមាននៃប្រភពទឹកក្នុងតំបន់ រួមទាំងស្រះ បឹង និងស្ទឹង នៅក្នុងភូមិទាំងនេះ និងភូមិជុំវិញ។

សកម្មភាពបែបនេះបង្កឱ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរផ្នែកច្បាប់ និងមនុស្សធម៌ក្រោមច្បាប់អន្តរជាតិ រួមមានពិធីសារហ្សឺណែវ អនុសញ្ញាអាវុធគីមី (CWC) ច្បាប់មនុស្សធម៌អន្តរជាតិ សន្ធិសញ្ញាសិទ្ធិមនុស្ស ច្បាប់បរិស្ថានអន្តរជាតិហាមឃាត់គ្រោះថ្នាក់ឆ្លងដែន និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសសម្រាប់កម្ពុជាដែលការពារអធិបតេយ្យភាពរបស់កម្ពុជា។

## សកម្មភាពបន្ទាន់ដែលបានស្នើសុំ៖

ខណៈពេលដែលក្រុមប៉ាន់ប្រមាណបន្តការប្រមូលទិន្នន័យបន្ថែម និងបន្តការធ្វើឲ្យច្បាស់លាស់ខាងវិទ្យាសាស្ត្រ យើងខ្ញុំអំពាវនាវជាបន្ទាន់នូវវិធានការអាទិភាពដូចខាងក្រោម៖

1. ការឆ្លើយតបអន្តរជាតិ៖ យើងជំរុញយ៉ាងខ្លាំងដល់អង្គការសហប្រជាជាតិ អាស៊ាន សហគមន៍ អន្តរជាតិ និងសង្គមស៊ីវិល ជាពិសេសអង្គការខាងផ្នែកបរិស្ថាន និងសិទ្ធិមនុស្ស ចាត់វិធានការភ្លាមៗ និងធ្វើការយ៉ាងសកម្ម ដើម្បីទប់ស្កាត់ការដាក់បាញ់ផ្សែងគីមីដែលអាចខុសច្បាប់បែបនេះ ជានាការការពារជនស៊ីវិល និងរក្សាបទឈប់បាញ់។

2. សកម្មភាពថ្នាក់ជាតិ៖ យើងអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើ ឬបន្តការស៊ើបអង្កេតស្ថានភាពនេះ និងផ្តល់ការសង្គ្រោះបន្ទាន់ដល់សហគមន៍ដែលរងផលប៉ះពាល់ជាបន្ទាន់ រួមទាំងទឹកទទួលទានដែលធានាសុវត្ថិភាព ជំនួយវេជ្ជសាស្ត្រ និងការស្តារបរិស្ថាន និងរក្សាការទទួលខុសត្រូវរបស់ខ្លួនក្នុងការស្វែងរកការទទួលខុសត្រូវចំពោះការរំលោភបំពានក្រោមច្បាប់អន្តរជាតិ។

លើសពីនេះ យើងសង្កត់ធ្ងន់ពីភាពចាំបាច់នៃការសិក្សាបច្ចេកទេសស៊ីជម្រៅឯករាជ្យដោយអង្គការសហប្រជាជាតិ និងអាស៊ាន (ASEAN) ដើម្បីវាយតម្លៃផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន។ ការស៊ើបអង្កេតវិទ្យាសាស្ត្រយ៉ាងហ្មត់ចត់ គឺចាំបាច់ដើម្បីកំណត់អត្តសញ្ញាណសារធាតុដែលបានប្រើ បញ្ជាក់ប្រភពដើមរបស់ពួកវា ធ្វើឲ្យមានគណនេយ្យភាព (ការទទួលខុសត្រូវទាំងស្រុងលើការប្រព្រឹត្ត) និងធានាយុត្តិធម៌ស្របតាមក្របខ័ណ្ឌច្បាប់អន្តរជាតិ។

យើងមានការព្រួយបារម្ភថា ការខ្វះការអនុវត្តសកម្មភាព ឬមិនអនុវត្តនឹងទៅជាការបរាជ័យក្នុងការការពារការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ បង្កគ្រោះថ្នាក់ដល់អធិបតេយ្យភាពរបស់កម្ពុជា និងបង្កឱ្យមានគ្រោះថ្នាក់បរិស្ថានរយៈពេលវែងជាមួយនឹងផលប៉ះពាល់ឆ្លងតាមព្រំដែន និងកំណត់អាទិភាពមិនបានល្អដល់ពិភពលោក។


សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

- ប្រធានអង្គការ CHRAC៖ លោក រស់ សុដ្ឋា លេខ 012 620 014;
  អ៊ីម៉ែល៖ sotharos@gmail.com
- នាយកប្រតិបត្តិ NGOF លោកសឿង សារឿន: លេខ 085 777 954;
  អ៊ីម៉ែល៖ saroeun@ngoforum.org.kh